# យកឈ្នះជំងឺ ភ្លេចភ្លាំង Alzheimer

## យុទ្ធនាការយល់ដឹងជាសាធារណៈអំពីជំងឺ ភ្លេចភ្លាំង

រដ្ឋកាលីហ្វ័រញ៉ាគឺជាទីស្នាក់អាស្រ័យសម្រាប់មនុស្សវ័យចំណាស់ដែលមានអាយុលើសពី 65 ឆ្នាំច្រើនជាងរដ្ឋដទៃទៀត។ គេបានធ្វើរោគវិនិច្ឆ័យឃើញថា ជំងឺ ភ្លេចភ្លាំង នឹងកើនឡើងទ្វេដងនៅឆ្នាំ 2040ចំពោះប្រជាជនកាលីហ្វ័រនីញ៉ា ដែលនេះវាជារឿងសំខាន់សម្រាប់យើងទាំងអស់គ្នាក្នុងការស្វែងយល់ពីអ្វីដែលអាចយកឈ្នះជំងឺភ្លេចភ្លាំងនិងជំងឺផ្សេងៗដែលពាក់ព័ន្ធនឹងជំងឺវង្វេងវង្វាន់ (ADRD)។

ទោះបីជាកត្តាហានិភ័យចម្បងចំពោះជំងឺភ្លេចភ្លាំងដោយសារវ័យចំណាស់ក៏ដោយ ប្រជាជនកាលីហ្វ័រញ៉ាទាំងអស់ សមនឹងមានវ័យចំណាស់ដែលប្រកបដោយសេចក្តីថ្លៃថ្នូរនិងសុវត្ថិភាព។ នៅឆ្នាំ 2019 អភិបាលរដ្ឋ Gavin Newsom បានបង្កើតក្រុមការងារដើម្បីការពារជំងឺភ្លេចភ្លាំង, ការត្រៀមលក្ខណៈនិងមាគ៌ាឆ្ពោះទៅមុខដើម្បីគូសបញ្ជាក់នូវអនុសាសន៍ទូទាំងរដ្ឋ ដែលទ្រទ្រង់បុគ្គលម្នាក់ៗ និងគ្រួសារដែលរស់នៅក្នុងរង្វង់មានជំងឺ ភ្លេចភ្លាំង, អ្នកថែទាំដែល ទ្រទ្រង់ពួកគេ, និងសហគមន៍ដែលរង ផលប៉ះពាល់ដោយជំងឺនេះ ។

### ធ្វើការរួមគ្នា យើងអាចយកឈ្នះជំងឺភ្លេចភ្លាំងបាន

ពលរដ្ឋកាលីហ្វ័រញ៉ាជាច្រើន គេចវេសពីការស្វែងរកជំនួយ សម្រាប់ជំងឺភ្លេចភ្លាំងដោយសារតែមិនបានដឹងនិងការមាក់ងាយ ។ “យកឈ្នះជំងឺភ្លេចភ្លាំង ឬ Take On Alzheimer's” គឺជាយុទ្ធនាការពហុភាសា, ពហុវប្បធម៌ ដែលមានគោលបំណងផ្លាស់ប្តូរការយល់ឃើញនិងកាត់បន្ថយការមាក់ងាយ ។ វាអប់រំសហគមន៍ចម្រុះអំពីសញ្ញាកត្តាហានិភ័យនិងវិធីលើកកម្ពស់សុខភាពខួរក្បាល ។



**តើពលរដ្ឋកាលីហ្វ័រញ៉ាត្រូវដឹងអ្វីខ្លះ អំពីជំងឺភ្លេចភ្លាំងនេះ?**

- ជំងឺភ្លេចភ្លាំង (អាល់ហ្សៃមឺរ) គឺជាមូលហេតុចម្បងទីពីរ នៃការស្លាប់នៅក្នុងរដ្ឋកាលីហ្វ័រញ៉ា
- ជំងឺភ្លេចភ្លាំងគឺជាប្រភេទជំងឺវង្វេងវង្វាន់ ដែលប៉ះពាល់ដល់ការចងចាំ, ការគិតនិងអាកប្បកិរិយា
- បច្ចុប្បន្ននេះ មនុស្សប្រហែល 690,000 នាក់ នៅក្នុងរដ្ឋកាលីហ្វ័រញ៉ាមានជំងឺនេះ
- ជម្ងឺភ្លេចភ្លាំងគឺជាស្ថានភាពជំងឺរ៉ាំរ៉ៃដែលមានន័យថា វាអាចគ្រប់គ្រងនិងកែលម្អសុខភាពខួរក្បាលរបស់អ្នក
- ជំងឺភ្លេចភ្លាំងទំនងអាចប៉ះពាល់ដល់ស្ត្រីនិងដល់មនុស្សចម្រុះជាតិសាសន៍
- មនុស្សភាគច្រើនដែលត្រូវបានគេធ្វើរោគវិនិច្ឆ័យថាមានជំងឺ ADRD មានអាយុ 65 ឆ្នាំឡើងទៅ ប៉ុន្តែសញ្ញាអាចចាប់ផ្តើមពីដំបូងនៅអាយុ 55 ឆ្នាំ

**សូមចូលទៅកាន់គេហទំព័រ TakeonALZ.com ដើម្បីស្វែងយល់បន្ថែមអំពីយុទ្ធនាការ និងវិធីដែលអ្នកអាចយកឈ្នះ ជំងឺ Alzheimer ។**